HONEYCOMB 3/2 (April 2002): 134–138



# Confronting Pornography: Choosing Life

*Glenn MILES*

Pornography is one of those things hard for Christians in the West to get upset about. It's a bit like drinking alcohol. Although it is acceptable for an anti-smoker to politely ask someone else to refrain from smoking, a person who admits to being a teetotaler is considered rather uptight. Similarly, if someone says something against pornography he or she might be considered prudish. In postmodern America and Europe, women's magazines increasingly urge women to get used to the fact that their boyfriends use pornography, and not get too upset by it. Viewing "girlie" magazines is considered a normal part of growing up. "Boys will be boys." So fathers are reluctant to educate their children on the dangers of pornography, even if they are aware of the pull and pain it causes even themselves.

Sex sells, and it's here to stay. MTV, spread by satellite and cable to the most remote corners of the earth, not only globalizes a culture of music and fashion, but normalizes a culture in which sex is a commodity that can be demanded.

In many cultures traditional values have kept sex secret, and in many Muslim countries modesty is considered so sacred that the whole female body, apart from slits for the eyes, is covered in a *bourdkar*. The Western media is horrified, but advocates of the system say that it honors women and provides them a form of protection.

In a country like Cambodia it is difficult to accurately estimate the effect of pornography on the culture, but it could be one of the reasons why sexual abuse and exploitation are so rampant. When I first visited the country in 1990 there were no billboards anywhere that did not promote a political agenda. But now advertising is ubiquitous, and billboards promote cigarettes and alcohol, promising success, health, and sex thereby. Unfortunately for the poor the opposite more likely results, as they use up precious resources. Furthermore the image of a perfect body that even those of us with normal healthy bodies envy is promoted. What must it do to the self-image of a person with a disability? Pornography not only exploits the person being photographed, but the viewer as well.

In the markets of Phnom Penh pirated sex videos are available for two dollars. These include not only soft porn, but portray every conceivable sexual act that most Christians have only known through descriptions in the Bible. Vendors make them less or more available depending on whether the authorities are clamping down, but everyone knows that anything can be resolved with some money under the table. Tourists are some of the customers, but more and more young people can be seen rummaging through cardboard boxes of explicit videos and VCDs.

It is difficult to prove that pornography leads to an increase in rape and sexual exploitation, but scripture indicates that it leads the voyeur down a slippery slope. Proverbs describes a set of doors. One is the doorway of a prostitute, where she calls out to those who pass by with promises of secret delights, but the guests who have entered the doorway are described as "dead" and "in the depths of Sheol."[1]

A different doorway can be chosen for those who listen to the Lord.[2] Those who watch daily at these doors can find wisdom, and "whoever finds me finds life." One door leads to life, the other to death. The passage goes on to describe some of the other consequences of choosing the wrong door—"those who miss me injure themselves, all who hate me love death." Pornography leads to death.

---

[1]Prov 9:13–18.

[2]Prov 8:32–36.

Christians may convince themselves that pornography is better than adultery because it affects only them, but those who have slowly, unwittingly become addicted to pornography will tell you how it destroyed their marriages and other relationships. I would suggest that missionaries and Christian workers are particularly vulnerable to this misconception and, using the excuse of needing to obtain information from the internet, are vulnerable to entering the private fantasy world of internet pornography.

So what does pornography do to a society? Although it is difficult to prove, I would suggest the following results stem from people wanting to experiment with sexual behavior they have seen:

- An increase in rape and sexual abuse in and outside the home
- An increase in the use of prostitutes
- An increase in the incidence of HIV/AIDS.

At the 2001 Evangelical Fellowship of Cambodia Youth Conference, one hundred forty-five attendees completed a survey on pornography, though each respondent did not necessarily answer all the questions. One hundred one males and forty-four females participated in the survey; forty-four were age 18 or under, fifty-three were age 19–21, and thirty-six were over age 22. Twelve respondents did not state their age.

The survey was completely confidential; completed forms were dropped anonymously in a box. The group was informed that the overall results would be made available to pastors and others involved in sex education after they had been analyzed.

One of the most interesting results of this survey concerned pornography. The number of males who have looked at pornographic literature *increased* according to age—from 27% below 18 years, to 38% at 19–21 years, to 47.2% at 22 years or over. However, among the females we find a different but disturbing trend—29.5% of girls under 18 years say they have read pornographic literature, compared to 6% for ages 19–21, and 3% for ages 22 and over. This may indicate that the aggressive advertising campaigns and lowering costs of literature aimed at girls may be proving successful.

Here are some further results of the survey:

| | Males | Females |
|---|---|---|
| Have viewed pornographic video | 33% | 3.5% |
| Have viewed pornography on the web | 2% | 0% |
| Have previously attended a sex education seminar | 28% | 14.5% |
| Source of sex education | | |
| parents | 34% | 12% |
| another relative | 19% | 5.5% |
| teachers | 50% | 17.2% |
| friends | 28% | 2% |
| pastor | 43% | 19% |
| magazines | 17% | 3.5% |
| videos | 14.5% | 2% |
| Know others their age who have had sex before marriage | 35% | 13% |
| Have had sex outside of marriage before becoming a Christian | 16% | 2% |
| Have had sex outside marriage since becoming a Christian | 4% | 1.5% |

Comparing statistics in the last two rows would seem to indicate that young people are influenced by their belief in Christianity. However it should be noted that the number of young people who refused to answer the last question was 22%, compared to 7.3% for the previous question.

It may be instructive to repeat this survey in future conferences, compare results, and note trends. This information could be used in the development of curriculum by the EFC Youth Commission and Servants, both of which are partners of Tearfund.

The results should stimulate pastors both to provide education themselves and to encourage Christian parents to do so. But they should also urge us to do something about the pornography industry.

In Cambodia, the Prime Minister has expressed concern about the growth of pornography, and the Evangelical Fellowship of Cambodia is planning a march against pornography later this year. They are also conducting Ruth and Boaz seminars for church youth on sexual awareness and appropriateness in relationships.

One problem with sexual exploitation here is that Cambodians sometimes blame either the UN soldiers in 1993 or today's tourists for the current level of sexual abuse and exploitation. But the fact is that it is happening in average "normal" Cambodian villages. It is probably also happening in Christian churches. It is easy to point the finger at others, but arguably more profitable to first remove the planks from our own eyes.

On an individual level we all need to take responsibility to protect ourselves and others. Internet screening is possible with software and programs that can be downloaded from the internet, e.g. surfonthesafeside.com. We can choose where we go and what we read. We can educate our children about sex before someone else does it for us. We can be role models in our relationships with our spouses and the way that we develop and maintain relationships with the opposite sex. We can lobby against child pornography through organizations such as Childnet (nigel@childnet-int.org). In short, we can choose life.

សំណុំនិកឃ្ញុំ ៣/២ (មេសា ២០០២)៖ ១៣៩-១៤៧



# ការជ្រើសរើសយកជីវិត ជាកិច្ចប្រឈមមុខទល់ នឹងរូបអាសអាភាស

*លោក គ្លេន ម៉ែល*

រឿងអាសអាភាសជាបញ្ហាមួយក្នុងបញ្ហាជាច្រើនដែលបង្កការលំបាកដល់គ្រីស្ទបរិស័ទនៅបណ្ដាប្រទេសនានាប៉ែកខាងបស្ចឹមប្រទេស ដែលធ្វើឲ្យមានការមិនសប្បាយចិត្តពីការមើលរឿងអាសអាភាសនោះ ។ គឺវាប្រហាក់ប្រហែលគ្នាទៅនឹងការផឹកស្រាដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះអ្នកមិនជក់បារីដែលនិយាយទៅកាន់អ្នកជក់ថា ខ្ញុំមិនចេះជក់ទេ សូមទៅជក់នៅកន្លែងផ្សេងទៅ នោះគេរាប់ថាជាការគួរសមដែលនិយាយបែបនោះទៅអ្នកជក់បារី តែបើមនុស្សណាម្នាក់និយាយថា ខ្ញុំមិនចេះផឹកស្រាទេ នោះគេរាប់មនុស្សនោះទុកថាជាមនុស្សព្រួយជ្រុលពេក ។ ការនេះស្រដៀងគ្នាទៅនិងការមើលរឿងអាសអាភាសដែរ បើសិនលោកអ្នកនិយាយអ្វីមួយដែលប្រឆាំងទាស់នឹងរូបអាសអាភាសនោះ គេអាចគិតថាអ្នកនោះប្រហែលជាបរិសុទ្ធពេក ។ នៅក្នុងសម័យចុងក្រោយនេះនៅសហរដ្ឋអាមេរិក និងនៅអឺរ៉ុប ទស្សនាវដ្ដីរបស់ស្ត្រីបានជំរុញលើកចិត្តស្ត្រីឲ្យស៊ាំនឹងហេតុការណ៍ដែលសង្សាររបស់គេបានមើលរូបអាសអាភាស ហើយបានលើក

ទឹកចិត្តដល់ស្ត្រីកុំឲ្យប្រកាន់ខឹងនឹងការបព្រឹត្តិរបស់សង្សាររបស់គេធ្វើអ្វី ។ ការមើលរូបភាពនៅក្នុង "ទស្សនាវដ្ដីបង្ហាញសាច់ស្រស់" របស់ស្ត្រីនោះ គឺគេរាប់ថាជារឿងធម្មតាក្នុងផ្នែកមួយនៃការចំរើនលូតលាស់របស់មនុស្ស ។ "កើតមកជាប្រុសត្រូវមានលក្ខណៈជាប្រុស" ។ ដូច្នេះឪពុកទាំងឡាយមានការអល់ឯកក្នុងការស្តីប្រដៅដល់កូនរបស់ខ្លួនស្ដីពីគ្រោះថ្នាក់នៃការមើលរូបអាសអាភាសនោះ សូម្បីតែគេបានដឹងថាមានការទាក់ទាញទឹកចិត្ត និងធ្វើឲ្យមានការឈឺចាប់ដោយព្រោះការមើលរូបភាពទាំងនោះក៏ដោយចុះ ក៏គេមិនបានស្តីប្រដៅដល់កូនដែរ ។

ការលក់ខ្លួន គឺនៅជាប់ជាប្រចាំនៅទីនេះទៅហើយ ។ *អ៊ីមធីវី* សាយភាយដោយសារប្រពន្ធ័ផ្កាយរណប និងទូរទស្សន៍ខ្សែកាប ក៏សាយភាយគ្រប់ទីកន្លែងទាំងអស់នៅក្នុងលោកយើងនេះ មិនគ្រាន់តែជាវប្បធម៌នៃតន្រ្តី និងការបង្ហាញម៉ូតទូទាំងសកលលោកប៉ុណ្ណោះទេ ប៉ុន្តែវាក្លាយជាទម្លាប់ធម្មតាមួយដែលសេចក្តីត្រូវការផ្នែកភេទក្លាយទៅជាពាណិជ្ជកម្មមួយបែបដែលអាចទាមទារយកបាន ។

នៅក្នុងទំនៀមទម្លាប់វប្បធម៌ដែលឲ្យតម្លៃលើភេទ គឺជាការមួយដែលគួររក្សាទុកជាការសម្ងាត់ ហើយនៅក្នុងបណ្តាលប្រទេសដែលកាន់សាសនាអ៊ីស្លាមជាច្រើន ការមិនបង្ហាញខ្លួនឲ្យគេឃើញនោះរាប់ទុកជាការដ៏ពិសិដ្ឋបំផុត ហេតុដូច្នេះហើយបានជារូបកាយរបស់ស្ត្រីទាំងមូលត្រូវតែគ្របបិទបាំងយ៉ាងជិតដោយប្រើស្បៃរុំមុខទុកតែប្រឡង់ភ្នែកតែប៉ុណ្ណោះ ។ ប្រព័ន្ធផ្សព្វផ្សាយរបស់ពួកលោកខាងលិចចម្លែកនៅក្នុងចិត្តយ៉ាងខ្លាំង ប៉ុន្តែគេគាំទ្រប្រព័ន្ធនោះជាសាធារណៈថា ការនោះបានផ្តល់កិត្តិយសដល់ស្ត្រី និងផ្តល់កិច្ចការពារដល់ពួកគេបានមួយបែបដែរ ។

នៅក្នុងប្រទេសមួយដូចជាប្រទេសកម្ពុជា មានការពិបាកណាស់ដើម្បីធ្វើការប៉ាន់ប្រមាណមើលឲ្យបានដឹងពិតប្រាកដពីផលប៉ះពាល់នៃរូប

អាសភាសទៅលើទំនៀមទម្លាប់នោះ ប៉ុន្តែវាអាចជាហេតុផលមួយដែលប្រាប់ឲ្យយើងដឹងថា ហេតុអ្វីបានមានការចាប់រំលោភ និងការជួញដូរផ្លូវភេទកើតឡើងផុលផុសខ្លាំងម្ល៉េះ ។ នៅពេលដែលខ្ញុំបានមកលេងប្រទេសនេះដំបូងកាលពីឆ្នាំ ១៩៩០ គ្មានឃើញមានផ្ទាំងរូបភាពធំៗតាំងនៅតាមផ្លូវ ហើយក៏គ្មានការឃោសនាពីការងារផ្នែកនយោបាយឡើយ ។ ប៉ុន្តែឥឡូវនេះមានផ្ទាំងរូបភាពធំៗផ្សព្វផ្សាយពាណិជ្ជកម្មគ្រប់ទីកន្លែងទាំងអស់ ហើយមានទាំងការផ្សព្វផ្សាយលក់បារី ស្រា សន្យាផ្តល់រង្វាន់ ឃោសនាផ្នែកសុខភាព និងថែមទាំងឃោសនាផ្នែកភេទផង ។ គួរឲ្យសោកស្តាយណាស់ការឃោសនាទាំងនោះហុចលទ្ធផលផ្ទុយទៅវិញទេចំពោះអ្នកក្រ ព្រោះគេខំចំណាយធនធានអស់ពីខ្លួនព្រោះតែចង់ដេញតាមសំណាងទាំងឡាយដែលមាននៅក្នុងការឃោសនានោះ ។ លើសពីនោះទៅទៀត រូបភាពដ៏ស្រស់ស្អាតដែលគេបានផ្សព្វផ្សាយឃោសនានោះ សូម្បីតែយើងមានសុខភាពល្អមាំមួនទៅហើយនោះ ក៏មានអារម្មណ៍ច្រណែនហើយប្រាថ្នាចង់បានរូបរាងដូចរូបដែលគេឃោសនានោះដែរ ។ ចុះទម្រាំបើអ្នកដែលមានភាពពិការវិញ តើតូចចិត្តនឹងខ្លួនឯងប៉ុណ្ណាទៅ? រឿង ឬរូបភាពអាសអាភាសនោះមិនគ្រាន់តែកេងប្រវ័ញ្ចមនុស្សដែលគេយកទៅថតរូបនោះទេ តែមនុស្សដែលអង្គុយមើលរូបនោះក៏ត្រូវគេកេងប្រវ័ញ្ចដែរ ។

នៅក្នុងផ្សារនានាក្នុងទីក្រុងភ្នំពេញ កាសែតវីដេអូរឿងអាសអាភាសដែលលួចចម្លងលក់នោះ មានតម្លៃតែ២ដុល្លារសហរដ្ឋអាមេរិកតែប៉ុណ្ណោះ ។ រូបភាពនោះមិនគ្រាន់តែជារូបភាពអាសអាភាសតិចតួចប៉ុណ្ណោះទេ តែវាបង្ហាញពីរបៀបរួមភេទគ្រប់បែបស្ទើរតែមិនអាចជឿបានដែលគ្រីស្តបរិស័ទភាគច្រើនបានដឹងការទាំងអស់បានតាមតែរយៈការបកស្រាយពីព្រះគម្ពីរប៉ុណ្ណោះ ។ អ្នកលក់រូបអាសអាភាសទាំងនោះអាចលក់បានតិច ឬច្រើនគឺវាអាស្រ័យលើអាជ្ញាធរដែលត្រួតត្រាមើលដោយរិតត្បិតចំពោះការនោះ

ប៉ុន្តែមនុស្សគ្រប់រូបដឹងថា អ្វីក៏ដោយគឺត្រូវតែមានច្រកចេញទៅបានដោយសារលុយដែលគេប្រើដើម្បីសូកប៉ាន់នោះ ។ អ្នកទេសចរណ៍ទាំងឡាយគឺជាម៉ូយសំខាន់ចំពោះរឿងនេះ ប៉ុន្តែគេសង្កេតឃើញយុវជនកាន់តែច្រើនឡើងៗបាននាំគ្នាមករើជជុះរកមើលកាសែតវីដេអូ និងវីស៊ីឌីទាំងឡាយណាដែលប្រអប់ខាងក្រៅបង្ហាញយ៉ាងច្បាស់អំពីរឿងអាសអាភាសនោះ ។

គឺមានការពិបាកណាស់ដើម្បីបង្ហាញថា ការមើលរូបអាសអាភាសនោះបណ្តាលឲ្យមានការចាប់រំលោភ និងការកេងប្រវ័ញ្ចផ្នែកភេទ ប៉ុន្តែបទគម្ពីរបានបង្ហាញថា ការនោះនាំឲ្យអ្នកមើលធ្លាក់ក្នុងចម្រេះភ្នំដ៏រអិលខ្លាំងមួយដែលមិនអាចឡើងរួចបានឡើយ ។ គម្ពីរសុភាសិតពណ៌នាអំពីច្រកទ្វារជាច្រើន ។ មានច្រកផ្លូវមួយនាំទៅរកកន្លែងស្រីពេស្យា ជាកន្លែងដែលនាងអង្គុយហៅអស់អ្នកដែលដើរកាត់តាមទីនោះដោយសន្យាថានឹងបានទទួលនូវការសប្បាយជាទីសម្ងាត់ ប៉ុន្តែភ្ញៀវដែលបានចូលតាមច្រកទ្វារនោះរាប់ទុកថាជាពួកអ្នក "ស្លាប់" និងសុទ្ធតែនៅក្នុងទីជម្រៅនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ទេ" [១] ។

ចំពោះអស់អ្នកដែលព្រមស្តាប់ព្រះអម្ចាស់ មានច្រកទ្វារផ្សេងអាចជ្រើសរើសយកបាន[២] ។ អស់អ្នកដែលសម្លឹងមើលទ្វារនេះរាល់ថ្ងៃអាចនឹងស្វែងរកបាននូវប្រាជ្ញា និង "អ្នកណាដែលរកខ្ញុំឃើញ នោះនឹងរកបានជីវិត" ។ មានទ្វារមួយដែលនាំទៅរកជីវិត និងទ្វារមួយទៀតនាំទៅរកសេចក្តីស្លាប់ ។ អត្ថបទនេះបន្តទៀតថា អ្នកណាដែលជ្រើសរើសទ្វារខុស នោះគឺ "អស់អ្នកដែលរកខ្ញុំមិនឃើញ អ្នកនោះធ្វើបាបខ្លួនឯង ហើយអស់អ្នកណាដែលស្អប់ខ្ញុំ អ្នកនោះស្រឡាញ់សេចក្តីស្លាប់វិញ" ។ ការមើលរូបអាសអាភាសនាំទៅរកសេចក្តីស្លាប់ ។

---

[១] *សុភាសិត ៩:១៣-១៨*

[២] *សុភាសិត ៨:៣២-៣៦*

គ្រីស្តបរិស័ទអាចនិយាយអះអាងថា ការមើលរូបអាសអាភាសនោះ គឺវាគ្រាន់បើជាងការប្រព្រឹត្តិអំពើផិតក្បត់ ព្រោះមានតែអំពើផិតក្បត់ទេដែលអាចមានឥទ្ធិពលលើជីវិតគ្រីស្តបរិស័ទបាន ប៉ុន្តែចំពោះអស់អ្នកដែលចាប់ផ្តើមបន្តិចម្តងៗដោយគ្មានបំណងនឹងមើលសោះ ក៏ចាប់ផ្តើមញៀនចំពោះការមើលរូបអាសអាភាសនឹងប្រាប់លោកអ្នកឲ្យដឹងថា តើការមើលរូបភាពអាសអាភាសវាបំផ្លាញជីវិតអាពាហ៍ពិពាហ៍ និងទំនាក់ទំនងដទៃទៀតរបស់គេខ្លាំងប៉ុណ្ណានោះ ។ ខ្ញុំសូមផ្តល់នូវយោបល់ណែនាំថា បណ្តាបេសកជន និងបុគ្គលិកបំរើការងារគ្រីស្តបរិស័ទ គឺជាជនងាយរងគ្រោះចំពោះការយល់ច្រឡំបែបនេះ ហើយប្រើពាក្យដោះសាថា ចង់បានពត៌មានបន្ថែមពីប្រព័ន្ធអ៊ិនធើណិតក៏ឆ្លៀតឱកាសទៅមើលពិភពអាថ៌កំបាំងនៃរូបអាសអាភាសនៅក្នុងប្រព័ន្ធអ៊ិនធើណិតនោះទៅវិញ ។

ដូច្នេះតើការមើលរូបអាសអាភាសនោះ មានឥទ្ធិពលប៉ះពាល់យ៉ាងណាចំពោះសង្គម? ទោះបីមានការពិបាកក្នុងការបង្ហាញពីផលប៉ះពាល់យ៉ាងណាក៏ដោយ ខ្ញុំសូមបង្ហាញពីលទ្ធផលដូចខាងក្រោមដែលមនុស្សជាច្រើនចង់ដកពិសោធន៍នូវរបៀបរួមភេទ ដែលគេបានឃើញតាមរឿងអាសអាភាសនោះគឺ៖

- មានការកើនឡើងនៃការចាប់រំលោភ និងការចាប់បង្ខំយ៉ាងកំរោលទាំងនៅក្នុងផ្ទះ និងនៅក្រៅផ្ទះ ។
- មានការកើនឡើងចំពោះការទៅរកស្រីបន ។
- មានការកើនឡើងចំពោះការឆ្លងជម្ងឺអេដស៍ ។

នៅពេលសន្និសីទរបស់យុវជនប្រិយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជាឆ្នាំ ២០០១ អ្នកចូលរួមចំនួនមួយរយសែសិបប្រាំនាក់ បានបំពេញលើក្រដាសស្ទង់មតិស្តីពីការមើលរូបអាសអាភាស អ្នកឆ្លើយនីមួយៗមិនចាំបាច់ឆ្លើយគ្រប់សំណួរទាំងអស់ក៏បាន ។ មានយុវជនមួយរយមួយនាក់ និងយុវនារីសែសិប

បួននាក់ ដែលបានចូលរួមឆ្លើយនូវសំណួរទាំងអស់នោះ គឺមានសែសិបបួននាក់ អាយុ ១៨ឆ្នាំ ឬក៏ក្រោម១៨ មានហាសិបបីនាក់ អាយុពី ១៩-២១ឆ្នាំ ហើយសាមសិបប្រាំមួយនាក់ អាយុ២២ឆ្នាំ ។ មានដប់ពីរនាក់ មិនបានប្រាប់ពីអាយុរបស់ខ្លួនឡើយ ។

ការស្ទង់មតិបានធ្វើដោយសម្ងាត់បំផុត គឺនៅពេលដែលគេបំពេញរួចហើយ ក្រដាសស្ទង់មតិនោះត្រូវយកទៅទម្លាក់ដាក់ក្នុងប្រអប់មួយ ។ យើងបានប្រកាសដល់ក្រុមអ្នកបំពេញលើក្រដាសស្ទង់មតិឲ្យដឹងថា លទ្ធផលសរុបនឹងត្រូវជូនទៅគ្រូគង្វាល និងអ្នកដទៃទៀតដែលធ្វើការងារទាក់ទងនឹងការហ្វឹកហ្វឺនផ្នែកភេទបន្ទាប់ពីការស្ទង់មតិនេះបានទទួលនូវការវិនិច្ឆ័យយ៉ាងល្អិតល្អន់រួចមក ។

លទ្ធផលមួយដែលគួរឲ្យចាប់អារម្មណ៍ជាងគេនៅក្នុងការស្ទង់មតិនេះ គឺទាក់ទងទៅនឹងរឿងអាសអាភាស ។ ចំនួនយុវជនដែលបានមើលរូបអាសអាភាសកើនឡើង យោងតាមអាយុរបស់គេគឺមានន័យថា មាន២៧% អាយុក្រោម១៨ឆ្នាំ មាន៣៨% អាយុចាប់ពី ១៩-២១ឆ្នាំ មាន៤៧% អាយុ២២ឆ្នាំឡើងទៅ ។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងចំណោមយុវនារីយើងឃើញថាមានការខុសប្លែក ប៉ុន្តែគួរឲ្យកត់សំគាល់យ៉ាងខ្លាំង គឺមាន ២៩.៥% អាយុក្រោម១៨ឆ្នាំ ធ្លាប់អានរឿងអាសអាភាស ប្រៀបទៅ៦% មានអាយុពី១៩-២១ឆ្នាំ ហើយ៣% អាយុពី ២២ឆ្នាំឡើងទៅ ។ ការនេះអាចបង្ហាញថា យុទ្ធនាការនៃការផ្សព្វផ្សាយពាណិជ្ជកម្ម និងការដាក់តម្លៃរឿងទាំងនោះឲ្យទាបដើម្បីដៅចំពោះយុវនារីនោះ អាចបង្ហាញថានឹងទទួលបានជោគជ័យ ។

នេះគឺជាលទ្ធផលបន្ថែមរបស់ការស្ទង់មតិនោះគឺ៖

| | យុវជន | យុវនារី |
|---|---|---|
| ធ្លាប់មើលវីដេអូរឿងអាសអាភាស | ៣៣% | ៣.៥% |
| ធ្លាប់មើលវីដេអូរឿងអាសអាភាសតាមអ៊ិនធើណិត | ២% | 0% |
| ធ្លាប់ចូលរៀនសិក្ខាសាលាអប់រំផ្លូវភេទ | ២៨% | ១៤.៥% |
| ប្រភពដែលបានទទួលការអប់រំផ្លូវភេទ | | |
| ពីឪពុកម្ដាយ | ៣៤% | ១២% |
| សាច់ញាតិបងប្អូន | ១៩% | ៥.៥% |
| គ្រូបង្រៀន | ៥០% | ១៧.២% |
| មិត្តភក្តិ | ២៨% | ២% |
| គ្រូគង្វាល | ៤៣% | ១៩% |
| ទស្សនាវដ្ដី | ១៧% | ៣.៥% |
| វីដេអូ | ១៤.៥% | ២% |
| ស្គាល់អ្នកដទៃដែលមានអាយុស្របាលៗគ្នាដែលបានរួម-ភេទមុនរៀបការ | ៣៥% | ១៣% |
| ធ្លាប់រួមភេទមុនរៀបការ មុនក្លាយជាគ្រីស្ទបរិស័ទ | ១៦% | ២% |
| ធ្លាប់រួមភេទមុនរៀបការ តាំងពីក្លាយជាគ្រីស្ទបរិស័ទ | ៤% | ១.៥% |

តាមការប្រៀបធៀបតាមចំនួនតួលេខនៅជួរចុងក្រោយ ហាក់បីដូចជាបង្ហាញថា យុវជនមានការប្រែប្រួលចំពោះការប្រព្រឹត្តិរបស់គេដោយសារតែជំនឿគ្រីស្ទបរិស័ទរបស់ខ្លួន ។ តែទោះជាយ៉ាងណាក៏ដោយ គួរឲ្យកត់សំគាល់ដែរថា យុវជនមួយចំនួនដែលបានបដិសេធមិនព្រមឆ្លើយនូវសំណួរចុងក្រោយ គឺមាន ២២% ប្រៀបទៅនឹង ៧.៣% ចំពោះសំណួរមុនសំណួរចុងក្រោយ ។

ការនេះគួរតែធ្វើសំណួរអំពីការស្ទង់មតិបែបនេះទៀតនៅពេលធ្វើសន្និសីទនាពេលអនាគត ដើម្បីប្រៀបធៀបនូវលទ្ធផលដែលទទួលបាន

និងកត់សំគាល់មើលពីសន្ទុះឈានទៅរកការអ្វីមួយដែលយើងត្រូវតែដឹង ។ ពត៌មានដែលយើងទទួលបានទាំងនោះអាចយកទៅប្រើសំរាប់បង្កើតកម្មវិធីសិក្សាដោយស្ទង់ការយុវជនប្រិយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជា និងអង្គការបំរើជនក្រីក្រ ដែលទាំងពីរគឺសុទ្ធតែជាដៃគូជាមួយអង្គការ *ធាហ្វាន់* ដូចគ្នា ។

លទ្ធផលដែលយើងទទួលបាននោះអាចពញ្ញាក់ស្មារតីដល់គ្រូគង្វាលទាំងឡាយ ដើម្បីផ្តល់នូវការអប់រំដោយខ្លួនឯងផ្ទាល់ និងជំរុញឲ្យឪពុកម្តាយគ្រីស្តបរិស័ទធ្វើការអប់រំដល់កូនចៅរបស់គេដែរចំពោះបញ្ហានេះ ។ ប៉ុន្តែការប្រមូលពត៌មានទាំងនោះនឹងជំរុញឲ្យយើងធ្វើអ្វីមួយចំពោះបញ្ហាឧស្សាហកម្មផ្នែករឿងអាសអាភាស ។

នៅក្នុងប្រទេសកម្ពុជា នាយករដ្ឋមន្ត្រីសម្តែងនូវការខ្វាយខ្វល់ចំពោះការកើតឡើងផុលផុសនូវរូបអាសអាភាស ហើយប្រិយសម្ព័ន្ធគ្រីស្តបរិស័ទកម្ពុជានឹងរៀបចំក្បួនដង្ហែមួយដើម្បីប្រឆាំងនឹងរូបភាពអាសអាភាសនៅចុងឆ្នាំនេះ ។ គេក៏បានរៀបចំសិក្ខាសាលា នាងរស់ និងបូអូស ដើម្បីអប់រំផ្នែកភេទ និងអប់រំផ្នែកទំនាក់ទំនងដ៏សមរម្យដល់យុវជន និងយុវនារី ។

បញ្ហាមួយនៅក្នុងចំណោមបញ្ហាទាំងអស់នៃការកេងប្រវ័ញ្ចផ្នែកភេទ គឺថាជនជាតិខ្មែរ ជួនកាលបន្ទោសដល់ពួកទាហានអង្គការសហប្រជាជាតិកាលពីឆ្នាំ ១៩៩៣ ឬដល់ពួកទេសចរណ៍នាពេលបច្ចុប្បន្ននេះ ចំពោះការកើតឡើងនូវការចាប់រំលោភ និងការកេងប្រវ័ញ្ចផ្លូវភេទនេះឯង ។ ប៉ុន្តែហេតុការណ៍នោះគឺថា រឿងរ៉ាវវាកំពុងតែកើតឡើងជាមធ្យម នៅក្នុងចំណោមមនុស្សសាមញ្ញធម្មតាដែលរស់នៅតាមភូមិនានានៃប្រទេសកម្ពុជា ។ រឿងនេះប្រហែលជាអាចកំពុងកើតឡើងតាមបណ្តាក្រុមជំនុំគ្រីស្តបរិស័ទដែរ ។ វាជាការងាយណាស់ដែលយើងចង្អុលដាក់អ្នកដទៃ ប៉ុន្តែការដែលប្រសើរនោះគឺយើងត្រូវដកយកធ្នឹមចេញពីភ្នែករបស់យើងជាមុនសិន ។

យើងម្នាក់ៗត្រូវទទួលខុសត្រូវចំពោះការការពារខ្លួនយើងផ្ទាល់ និងការការពារដល់អ្នកដទៃ ។ ដើម្បីច្រោះប្រព័ន្ធ អ៊ិនធើណិត យើងអាចប្រើកម្មវិធី និង សហ្វវែរ (Software) មួយបែបយកមកបញ្ចូលនៅក្នុងប្រព័ន្ធអ៊ិនធើណិតរបស់យើង ឧទាហរណ៍ដូចជា surfonthesafeside.com. ។ យើងអាចជ្រើសរើសកន្លែងដែលយើងត្រូវទៅ និងអ្វីដែលយើងត្រូវអាន ។ យើងអាចអប់រំកូនរបស់យើងអំពីរឿងភេទឲ្យបានមុនពេលអ្នកផ្សេងទៀតមកអប់រំជំនួសយើង ។ យើងអាចធ្វើជាគំរូនៅក្នុងទំនាក់ទំនងជាប្ដីនិងប្រពន្ធរបស់យើង ហើយបង្ហាញពីរបៀបដែលយើងអាចបង្កើតទំនាក់ទំនង និងរក្សានូវទំនាក់ទំនងនោះជាមួយនឹងអ្នកដែលមានភេទផ្ទុយពីយើង ។ យើងអាចរៀបចំការប្រឆាំងទំនាស់ជាមួយនឹងការធ្វើពាណិជ្ជកម្មរឿងអាសអាភាសចំពោះកុមារតាមរយៈអង្គការនានាដូចជា អង្គការ Childnet (nigel@childnet-int.org) ។ និយាយឲ្យខ្លីគឺ យើងអាចជ្រើសយកជីវិត មិនជ្រើសយកសេចក្ដីស្លាប់ទេ ។